ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែររងគ្រោះ១៦នាក់ ពីប្រទេសឥណ្ឌូនេស៊ី

======

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឥណ្ឌូនេស៊ី សហការជាមួយអាជ្ញាធរឥណ្ឌូនេស៊ី និងអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) បានរៀបចំមាតុភូមិនិវត្តន៍ ជូនពលរដ្ឋខ្មែររងគ្រោះចំនួន**១៦នាក់** (ក្នុងចំណោម១៨នាក់) ដែលជាពលករលើទូកនេសាទឈ្មោះ **KM.JHF 6525 T** បន្ទាប់ពីពួកគេត្រូវបានឃាត់ខ្លួនមួយរយៈនៅការិយាល័យអន្តោប្រវេសន៍ប្រចាំទីក្រុង **Tanjung Pinang** ប្រទេសឥណ្ឌូនេស៊ី និងក្រោយពីស្ថានទូតនិងអង្គការIOM បានបញ្ចប់ការសាកសួរ ដើម្បីកំណត់អត្តសញ្ញាណ រួចមក។

ពលរដ្ឋខ្មែររងគ្រោះទាំង**១៦នាក់** ត្រូវមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** តាមការរៀបចំនិងកាលបរិច្ឆេទដោយឡែកពីគ្នា ដូចខាងក្រោម៖

- ក្រុមទី១ មានចំនួន៨នាក់ បានមកដល់នៅថ្ងៃទី**២៤ មករា** ឆ្នាំ**២០១៧** វេលាម៉ោង**១៩:៣៥** នាទី
- ក្រុមទី២ មានចំនួន៨នាក់ នឹងមកដល់នៅថ្ងៃទី**៣០ មករា** ឆ្នាំ**២០១៧** វេលាម៉ោង**១៩:៣៥** នាទី។

ក្រៅពីនេះ តាមការណែនាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថានទូតកម្ពុជាប្រចាំប្រទេសឥណ្ឌូនេស៊ី កំពុងទាមទារប្រាក់ខែនិងផលប្រយោជន៍ផ្សេងៗទៀតពីម្ចាស់ទូកនេសាទ ជូនពលករខ្មែរទាំង**១៨នាក់**ផងដែរ។ ពលករទាំងអស់មានសុខភាពល្អធម្មតា ទទួលបានកន្លែងស្នាក់នៅសមរម្យ និងអាហារបរិភោគគ្រប់គ្រាន់ អំឡុងពេលជាប់ឃុំនៅការិយាល័យអន្តោប្រវេសន៍ប្រចាំទីក្រុង **Tanjung Pinang** ។

សូមរំលឹកថា ពលរដ្ឋខ្មែរទាំង**១៨នាក់** មានអាយុចន្លោះពី១៧ឆ្នាំទៅ៥៨ឆ្នាំ មកពីខេត្តកំពង់ចាម ត្បូងឃ្មុំ ព្រៃវែង កំពត និងកំពង់ធំ បានចូលក្នុងប្រទេសថៃ នៅចុងខែមិថុនា ឆ្នាំ២០១៦ ស្នាក់នៅក្នុងខេត្តប៉ាតានី ជាមួយមិត្តភក្តិនិងបងប្អូន ហើយបន្ទាប់មក ត្រូវបានម្ចាស់ទូកនេសាទនាំទៅនេសាទនៅខេត្ត **Endau** ប្រទេសម៉ាឡេស៊ី។ ម្ចាស់ទូកនេសាទ បានសន្យាជាមួយពួកគាត់ថា នឹងផ្តល់ប្រាក់ខែយ៉ាងតិច**៥៣ន់បាត** ក្នុង១ខែ ឬច្រើនជាងនេះ ប្រសិនបើរកត្រីបានច្រើន និងធ្វើការនេសាទនៅក្នុងដែនសមុទ្រម៉ាឡេស៊ីតែប៉ុណ្ណោះ។ ពួកគេត្រូវធ្វើការយ៉ាងតិច១៥ម៉ោងក្នុង១ថ្ងៃ ហើយការសម្រាកនិងអាហារបរិភោគ មិនបានគ្រប់

គ្រាន់ឡើយ។ ក្រោយពីនេសាទបានជាង២០ថ្ងៃ ទូកនេសាទដែលមានឈ្មោះ **KM.JHF 6525 T** នោះ បានចូលនេសាទដោយគ្មានការអនុញ្ញាតក្នុងដែនទឹកឥណ្ឌូនេស៊ី រួចត្រូវបានឃាត់ដោយឆ្មាំសមុទ្រឥណ្ឌូនេស៊ី។

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ពលករខ្មែរទាំង១៨នាក់ ត្រូវបានអាជ្ញាធរឥណ្ឌូនេស៊ីឃុំខ្លួនបណ្តោះអាសន្ន នៅការិយាល័យអន្តោប្រវេសន៍ **Immigration Class III Tarempa** ប្រចាំកោះ**Riau**។ បន្ទាប់មក នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ពលករខ្មែរចំនួន១៦នាក់ (ក្នុងចំណោម១៨នាក់) ត្រូវបានបញ្ជូនបន្តទៅការិយាល័យអន្តោប្រវេសន៍ប្រចាំទីក្រុង **Tanjung Pinang** តាមសំណើសុំរបស់ស្ថានទូត និងអង្គការIOM ដើម្បីសម្រួលក្នុងការធ្វើដំណើរទៅសម្ភាសនិងកំណត់អត្តសញ្ញាណ ខណៈដែលពលករ២នាក់ផ្សេងទៀត ត្រូវបានការិយាល័យអន្តោប្រវេសន៍ប្រចាំកោះ **Riau** ស្នើទុកសម្រាប់ធ្វើជាសាក្សី ដើម្បីកាត់ទោសម្ចាស់ទូកនេសាទ។ ចាប់ពីថ្ងៃទី១០ ដល់ទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៦ តំណាងស្ថានទូតនិងអង្គការ IOM បានធ្វើការសម្ភាសន៍ផ្ទាល់ជាមួយពលករខ្មែរទាំង១៦នាក់ និងកំណត់បានថា ពួកគេពិតជាជនរងគ្រោះជនជាតិខ្មែរ ប្រាកដមែន។

ចំណែកពលរដ្ឋខ្មែររងគ្រោះ២នាក់ផ្សេងទៀត ត្រូវបានសម្ភាសនិងកំណត់អត្តសញ្ញាណរួចហើយ រង់ចាំការត្រឡប់មកកម្ពុជាវិញក្នុងពេលឆាប់ៗខាងមុខនេះ ក្រោមការសម្របសម្រួលរបស់ស្ថានទូត អាជ្ញាធរឥណ្ឌូនេស៊ី និងអង្គការIOM នៅទីក្រុងហ្សាកាតា៕

ភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ